# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារគារីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥
- យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.**

តែងតាំង លោក ម៉ែនសុន សម័យ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅថា "**មេធាវីសារការី**" ។
~~~~~

**មាត្រា ២.**

**មេធាវីសាររការី**ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.**

**មេធាវីសាររការី**មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ, ចលនវត្ថុ និង អចលនវត្ថុ ជាអាទិមាន :

ក- ទទួល និង ធ្វើ ឬ ចារឹកបញ្ជាក់ និង ប្រថាប់ត្រា នូវលិខិតសម្មតតិយុត្តិ ឬ កិច្ចសន្យាទាំងឡាយ ដើម្បីងាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ- ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ, ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្តីដើម ឬសេចក្តីចម្លង នៃលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ- កិច្ចការនេះត្រូវពិនិត្យ, អានឱ្យអស់សេចក្តី និង ចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប **មេធាវីសាររការី** ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤.**

**មេធាវីសាររការី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០.០០ ( ប្រាំមួយរយលានរៀល) នៅធានាគារជាតិនៃកម្ពុជា សំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ និង ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ- កាលប្បវត្តិ